ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែកក្កដា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ អង្គប្រជុំដឹកនាំដោយឯកឧត្តម **គន់ ទិព្វុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តម **គន់ ទិព្វុល** បានសំដែងអំណរសាទរដល់ថ្នាក់ដឹកនាំនិងមន្រ្តីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែកក្កដា ឆ្នាំ ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្រ្តីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាក និងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានល្អប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវា

ងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានា សំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។

ក្នុងខែកក្កដា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣៦៤.១៨៨ លានរៀល (គិតជាដុល្លារ ៩១,១ លានដុល្លារ) ដែលចំណូលនេះមានការកើនឡើងលើសខែមិថុនា ប្រមាណស្មើនឹង ១៦,២% ក្នុងនោះ ថវិកាជាតិកើនឡើងចំនួនស្មើនឹង ១៥,២% ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ កើនឡើងចំនួនស្មើនឹង ២២,១%។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែកក្កដា ឆ្នាំ២០១៣ មានការកើនឡើងស្មើនឹង ៣៣,៧% ។

ក្នុងរយៈពេលប្រាំពីរខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធដារ និងបង់ចូលថវិកាជាតិបានចំនួនស្មើនឹង ៦២,៧% នៃគោលដៅកំណត់ដោយច្បាប់ ក្នុងនោះថវិការដ្ឋសម្រេចបានចំនួនស្មើនឹង ៦៥,៣% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានចំនួនស្មើនឹង ៤៦,៩៧%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់ឆ្នាំ២០១៤នេះ មានការកើនឡើងចំនួនស្មើនឹង ១៦,១% ។



ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលតាមប្រភេទពន្ធសំខាន់ៗ មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ពន្ធលើប្រាក់បៀវត្សកើនឡើងចំនួនស្មើនឹង ៣១,៧% ពន្ធលើប្រាក់ចំណេញកើនឡើងចំនួនស្មើនឹង ២៥,៥% អាករលើតម្លៃបន្ថែមកើនឡើងចំនួនស្មើនឹង ១៦,៥% និងអាករពិសេសកើនឡើងចំនួនស្មើនឹង ៨,១% ។

បើប្រៀបធៀបទៅនឹងរយៈពេល ០៧ខែ ដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ចំណូលពន្ធតាមសកម្មភាពអាជីវកម្ម មានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០,៤៦% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦៥,៩៥% ផលិតភេសជ្ជៈកើនឡើងប្រមាណ ២១,២៩% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៣២,៩៤% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៦,៣៥% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤០,២០% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ១៤,៤៨% ទូរគមនាគមន៍កើនឡើងប្រមាណ ១១,០៨% លក់ផលិតផលឱសថកើនឡើងប្រមាណ ២០១,៥៤% លក់ភេសជ្ជៈកើនឡើងប្រមាណ ២៧,៤៨% ផលិតថ្នាំជក់កើនឡើងប្រមាណ ១៣,៤៥% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៤០,៦៦% ផលិតម្ហូបអាហារ

កើនឡើងប្រមាណ ៨១,៩៥% អាជីវកម្មអចលនទ្រព្យកើនឡើងប្រមាណ ១១០,១១% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៦៤,៤៥% និងលក់គ្រឿងសំណង់ កើនឡើងប្រមាណ ២.៥៨៣,៧% ។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែ របស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ II-របាយការណ៍វឌ្ឍនភាពស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ III-វឌ្ឍនភាពនៃការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស IV- វឌ្ឍនភាពការងារផ្នែកតាមផែនការសកម្មភាពដោះស្រាយបញ្ហាជាក់ស្តែងរបស់អគ្គនាយកដ្ឋានពន្ធដារ V-ការចូលរួមមតិរបស់សមាជិកអង្គប្រជុំ ចំពោះលទ្ធផលការងារប្រមូលចំណូល និង VI- បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឱ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ អគ្គនាយកដ្ឋានបានដាក់ចេញនូវទិសដៅ និងវិធានការមួយចំនួនដូចខាងក្រោម ÷

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ។

- បន្តជំរុញអនុវត្តនូវគោលការណ៍ និងផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានដូចភ្លៀងរលឹម ជាពិសេសយុទ្ធនាការនៃការចាត់បញ្ចូលទៅរបបស្វ័យប្រកាស នូវអាជីវកម្មបង់ពន្ធតាមរបបម៉ៅការដែលមានផលរបរខ្ពស់។

- ពង្រឹងការអនុវត្តប្រកាសស្តីពីការទូទាត់បំណុលពន្ធ ដើម្បីពង្រឹងការប្រមូលបំណុលពន្ធ។

- បន្តជំរុញល្បឿនការងាររៀបចំកម្មវិធីចរចារបស់គណៈកម្មការអន្តរក្រសួង ដើម្បីដឹកនាំការចរចាកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA)។

- បន្តកែលំអការគ្រប់គ្រង និងទិន្នន័យរបស់អ្នកជាប់ពន្ធ ឱ្យបានល្អប្រសើរជាងមុន ប្រកបដោយតម្លាភាពនិងគណនេយ្យភាព ដោយខិតខំអនុវត្តឱ្យបានចប់សព្វគ្រប់រាល់គម្រោងធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីឱ្យអ្នកជាប់ពន្ធ ដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច (E-Filing, E-payment)។ ព្រមជាមួយនេះ រៀបចំសម្រួល ដំណើរការសង្វាក់ផលិតកម្មការងារ (Business Process) នៃការដាក់លិខិតប្រកាសបង់ពន្ធរបស់អ្នកជាប់ពន្ធ។

- បន្តរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មាននានា ដោយរៀបចំបង្កើត Spots អប់រំ ឬឯកសារ រូបភាពខ្លីៗ ឬសេចក្តីប្រកាសព័ត៌មាន ជាដើម ដោយមិនត្រឹមតែពន្យល់ណែនាំអ្នកជាប់ពន្ធនូវប្រភេទពន្ធនីមួយៗប៉ុណ្ណោះទេ ក៏ប៉ុន្តែពន្យល់ពីនីតិវិធីនៃការបង់ពន្ធ ការធ្វើការកែទម្រង់ និងអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

- បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីប្រព័ន្ធពន្ធដារកម្ពុជា និងប្រភេទពន្ធផ្សេងៗនៅភ្នំពេញ និងខេត្តមួយចំនួន ព្រមទាំងបានរៀបចំជា Spots អប់រំខ្លីៗ ដើម្បីចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍នូវប្រភេទពន្ធមួយចំនួន ដូចជាពន្ធលើប្រាក់ចំណេញ និងអាករលើតម្លៃបន្ថែម ជាដើម។

- ជំរុញបញ្ចប់ជាស្ថាពរនូវការបង្កើតមជ្ឈមណ្ឌលរក្សាទុកទិន្នន័យ (Data Center) ។ ការបង្កើតនូវមជ្ឈមណ្ឌលរក្សាទុកទិន្នន័យនេះឡើង គឺសម្រាប់រក្សាទុករាល់ឯកសាររបស់អ្នកជាប់ពន្ធពីគ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ ។

- បន្តអប់រំណែនាំមន្ត្រីគ្រប់លំដាប់ថ្នាក់ឲ្យធ្វើការផ្លាស់ប្តូរឥរិយាបថ ផ្នត់គំនិត (Mindset) ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដោយមិនត្រូវប្រើពាក្យគំរោះគំរើយ ប៉ុន្តែត្រូវទន់ភ្លន់ គោរពវិន័យការងារ ក្រមសីលធម៌វិជ្ជាជីវៈ និងបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់ ពោលគឺត្រូវម៉ឺងម៉ាត់ខាងទិដ្ឋភាពច្បាប់ ក្នុងការឆ្លើយតបទៅអ្នកជាប់ពន្ធ។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**អគ្គនាយកដ្ឋានពន្ធដារ**